**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ ប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៨សសរ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៤២ សសរ ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការបន្ថែមសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១:** ត្រូវបាននិរាករណ៍សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៨សសរចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤២ សសរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការបន្ថែមសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត។

www.pheakdeylaw.com

**ប្រការ ២:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀតដូចខាងក្រោម៖

១- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធាន

២- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធានអចិន្ត្រៃយ៍

៣- ឯកឧត្តម **ជា ម្ងារ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៥-អភិបាលខេត្តជាប់ព្រំដែនដែលមានច្រកទ្វារព្រំដែនអន្តរជាតិ អនុប្រធាន

៦- ឯកឧត្តម **ស៊ូ តិរិទ្ធ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧- ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការ សមាជិក

៨-ឯកឧត្តម **ហោ សារុន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិកនិងជាលេខាធិការ

៩-ឯកឧត្តម **លេង ទី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១០-ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ សេន** អគ្គនាយករងនៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការនយោបាយនៃក្រសួងការពារជាតិ សមាជិក

១១- ឯកឧត្តម **ឡាយ ឫទ្ធី** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ពិន ពិសិដ្ឋ** ប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

១៣-លោក **ហង្ស ប៊ុណ្ណារ៉ាក់** អគ្គនាយករងនៃក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់សមាជិក

១៤- លោក **ស៊ុំ ណារុន** អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូលក្រសួងពាណិជ្ជកម្មសមាជិក

១៥-លោក **ប្រាក់ សុវណ្ណារ៉ា** អគ្គនាយករងបេតិកភ័ណ្ឌនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១៦-ឧត្តមសេនីយ៍ទោ**ញាណ ទិមុល** ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

១៧-លោក **ឃុន សុវណ្ណនេត្រ** ប្រធានការិយាល័យលិខិតឆ្លងដែននិងទិដ្ឋាការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៨- លោក **ឆាយ រតនៈ** ប្រធានការិយាល័យជាតិធានារ៉ាប់រងកម្ពុជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៩- លោក **អ៊ុច សុផាន់ណា** អនុប្រធានការិយាល័យធានារ៉ាប់រងកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២០- លោក **ជា ចំនួមុន្នី** អនុប្រធានការិយាល័យចត្តាឡីស័កក្រសួងសុខាភិបាល សមាជិក

**ប្រការ ៣:** គណៈកម្មការអន្តរក្រសួងនេះ មានមុខងារ និងភារកិច្ចដូចតទៅ :

- ជំរុញអនុវត្តសេចក្តីជូនដំណឹងលេខ ៤១៣ សជណ សរ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យមានប្រសិទ្ធភាព ដើម្បីរៀបចំរបៀបរៀបរយ សណ្តាប់ធ្នាប់ និងសម្រួលការដឹកជញ្ជូន និងការធ្វើដំណើររបស់ភ្ញៀវទេសចរ និងអ្នកដំណើរនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀតឱ្យបានល្អប្រសើរ។
- សិក្សារៀបចំតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀតឱ្យមានហេដ្ឋារចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ។

www.pheakdeylaw.com

- លុបបំបាត់និងបោសសម្អាតភាពអសកម្មទាំងឡាយ និងភាពអនាធិបតេយ្យគ្រប់បែបយ៉ាង ដែលនាំឱ្យប៉ះពាល់ និងរំខានដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ។
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍ ដោយលើកយោបល់ជាវិធានការដោះស្រាយជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**ប្រការ ៤:** គណៈកម្មការអន្តរក្រសួងនេះមានលេខាធិការដ្ឋានមួយជាជំនួយការដែលមានទីតាំងនៅក្រសួងទេសចរណ៍ និងចំណាយថវិការបស់ក្រសួងទេសចរណ៍។

**ប្រការ ៥:** សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៅតាមសំណូមពរ និងទំហំការងារជាក់ស្តែង។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សាលាខេត្ត និងមន្ទីរទេសចរណ៍ខេត្តជាប់ព្រំដែនដែលមានច្រកទ្វារអន្តរជាតិ ប្រធាន អនុប្រធាន និងសមាជិកដែលមានរាយនាមក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល__*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com